**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣៣៣❖៣៣៣

MakMax

Taiyo Kogyo (Cambodia) co., ltd

Date: July 02, 2020

# កិច្ចព្រមព្រៀងអំពីនីតិវិធីទូទាត់ជាមួយកម្មករនិយោជិត

**កម្មវត្ថុ:** សំណើរសុំព្យួរកិច្ចសន្យាការងារចំនួន៦០ថ្ងៃ ចាប់ពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២០

**យោង៖** លិខិតលេខ ០៤៥/២០ ក.ប/ស.ណ.ន ខ.ល របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

ក៣-កាតព្វកិច្ចផ្សេងទៀតរបស់ម្ចាស់ ឬនាយករោងចក្រ សហគ្រាស គ្រឹះស្ថានក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍៖

- សម្រាប់រោងចក្រ សហគ្រាស គ្រឹះស្ថានក្នុងវិស័យកាត់ដេរ ត្រូវផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៣០ដុល្លារអាមេរិក សម្រាប់កម្មករនិយោជិតម្នាក់ៗ ក្នុង១ខែ ក្នុងនោះ៖
  - ចំនួន ១០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
  - ចំនួន ២០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
  - ចំនួន ៣០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ២១ថ្ងៃ ដល់ ១ខែ។
- សម្រាប់សហគ្រាស គ្រឹះស្ថានក្នុងវិស័យទេសចរណ៍ ត្រូវពិនិត្យផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមដល់កម្មករនិយោជិត តាមលទ្ធភាពនិងការស្ម័គ្រចិត្ត នៅក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ ព្រមទាំងកំណត់នីតិវិធីនៃការបើកប្រាក់ឧបត្ថម្ភបន្ថែមនេះ។

ក៤-សម្រាប់កម្មករនិយោជិត ត្រូវ៖

- ផ្តល់លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលេខទូរស័ព្ទផ្ទាល់ខ្លួនដែលអាចទាក់ទងបាន ដល់ម្ចាស់ ឬនាយករោងចក្រ សហគ្រាស គ្រឹះស្ថានក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ ដើម្បីចងក្រងជាបញ្ជីផ្តល់ជូនក្រសួង យកទៅរៀបចំនីតិវិធីបើកផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលដែលមានចំនួន ៤០ដុល្លារអាមេរិក ក្នុង១ខែ តាមរយៈធនាគារឯកទេសវីង ទៅកម្មករនិយោជិត។

  ប្រសិនបើគ្មានលេខទូរស័ព្ទផ្ទាល់ខ្លួន ត្រូវផ្តល់លេខទូរស័ព្ទជារបស់ប្តី ប្រពន្ធ កូន ឪពុក ម្តាយ ឬបងប្អូនបង្កើត និងមិនត្រូវផ្លាស់ប្តូរលេខទូរស័ព្ទជាដាច់ខាត។
- ទទួលបានប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាល តាមរយៈភ្នាក់ងារវីង ដូចខាងក្រោម៖
  - ចំនួន ១៥ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
  - ចំនួន ៣០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
  - ចំនួន ៤០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ២១ថ្ងៃ ដល់ ១ខែ។
- ក្រោយពេលព្យួរកិច្ចសន្យាការងារចំនួន ១០ថ្ងៃ កម្មករនិយោជិត នឹងទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង ដែលជម្រាបដំណឹងអំពីចំនួនទឹកប្រាក់ដែលត្រូវទទួលបាន។

យោងតាមកម្មវត្ថុ និងយោងខាងលើ ដោយជំងឺកូវីដ១៩ មានការរីករាលដាលខ្លាំង នៅប្រទេសជប៉ុន និងទូទាំងពិភពលោក បានធ្វើអោយមានផលអវិជ្ជមានដល់រោងចក្រ ផងដែរ គណគ្រប់គ្រងក្រុមហ៊ុនតំរូវអោយកម្មករចំនួនសាមសិបនាក់ ព្យួរកិច្ចសន្យាការងារក្នុងខែសីហា,កញ្ញា ឆ្នាំ២០២០ ចាប់ពីថ្ងៃ២១ ខែកក្កដា ឆ្នាំ២០២០ រហូតដល់ថ្ងៃ ១៨ ខែកញ្ញា ឆ្នាំ២០២០។ ដូចនេះក្រុមហ៊ុនត្រូវមានភារកិច្ចត្រូវផ្តល់ប្រាក់ឧបត្ថមដល់កម្មករនិយោជិត

ម្នាក់ៗចំនួន ៦០ ដុល្លារអាមេរិចសំរាប់ការព្យួរកិច្ចសន្យាការងារចំនួន៦០ថ្ងៃ ដោយក្រុមហ៊ុននឹងបើកផ្តល់អោយ ៣០ ដុល្លារអាមេរិចក្នុងមួយខែរៀងរាល់ចុងខែតាមរយះ គណនីធនាគារ ACLEDA BANK PLC របស់កម្មករនិយោជិតនីមួយៗ។

**ស្នាមមេដៃឬ ហត្ថលេខា**
**តំណាងក្រុមហ៊ុន**

អនុប្រធានក្រុមហ៊ុន
YUMI HASDEGAWA

**កម្មករនិយោជិត**

| | | | |
|---|---|---|---|
| ផន គឹមសី | ផាន់ គន្ធា | វ៉ាន់ ចន្ធា | ម៉ៅនី |
| សឿង ភាន់ | ឈុន សុឃីម | សុន សាន | ស្ហួ ណាន |
| ព្រាប ណាប់ | កែ លីដា | អាន ស្រីយ៉ា | កែប រត្ថា |



សៅ សម្ផស្ស



ភាច កាណាន់



ថា ចាន់ធឿន



អាន ស្រៀន



ម៉ៅ ផល្លា



ឃាន ឈី



ផាន អាន



ម៉ូ រទ្ធី



ជួន សារី



ឃ៊ិន សារឿង



រ៉ល្ល តាំងឃី



នៅ សុខនីម



សៃ សោភា



អ៊ីន ស្រីនាង



ឈឹង ស្រីប៉ាច



ឡឹង ទិត្យ



សុំ ណី



ខិល ស៊ីណា